ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៦២៩ ......សហវ.ប្រក

# ប្រកាសរួម

## ស្តីពី

## ការពិន័យជាប្រាក់ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីការងារ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

រដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- ប្រកាសអន្តរក្រសួងលេខ ៣៧៧ ប.ក/ប្រក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រាក់ឈ្នួលយោងប្រចាំថ្ងៃ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងយុត្តិធម៌
- ប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់
- សារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់
- សារាចរណែនាំលេខ ០០១ សហវ.ចមព ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីគោលការណ៍ និងនីតិវិធីផ្តល់រង្វាន់លើកទឹកចិត្តលើការផ្តល់សេវាសាធារណៈ
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .-**

អនុញ្ញាតឱ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អនុវត្តការប្រមូលចំណូលពីការពិន័យជាប្រាក់ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីការងារ ដើម្បីជាគុណប្រយោជន៍ដល់ថវិកាជាតិ។

**ប្រការ២ .-**

កម្រិតទឹកប្រាក់នៃការពិន័យចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីការងារ ត្រូវបានកំណត់ផ្អែកទៅតាមស្ថានទម្ងន់នៃអំពើល្មើស និងចែកចេញជាពីរកម្រិត គឺកម្រិតទឹកប្រាក់ពិន័យស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងកម្រិតទឹកប្រាក់ពិន័យអនុលោមតាមការសម្រេចរបស់សាលាជម្រះក្តី ដូចមានចែងលម្អិតនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមនេះ។

ចំនួនទឹកប្រាក់ដែលត្រូវពិន័យទៅតាមករណីប្រព្រឹត្តល្មើសនីមួយៗ ត្រូវបានគណនាផ្អែកតាមប្រាក់ឈ្នួលយោងប្រចាំថ្ងៃ និងចំនួនថ្ងៃដែលត្រូវទទួលរងការពិន័យ។ ចំពោះប្រាក់ឈ្នួលយោងប្រចាំថ្ងៃ ត្រូវអនុលោមតាមការកំណត់នៃប្រកាសអន្តរក្រសួងលេខ ៣៧៧ ប.ក/ប្រក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រាក់ឈ្នួលយោងប្រចាំថ្ងៃ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងយុត្តិធម៌ ឬ ផ្អែកតាមប្រកាសអន្តរក្រសួងរវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងយុត្តិធម៌ ស្តីពីការកែសម្រួលប្រាក់ឈ្នួលយោងប្រចាំថ្ងៃ ក្នុងករណីមានការកែសម្រួលប្រកាសអន្តរក្រសួងលេខ ៣៧៧ ប.ក/ប្រក ខាងលើនេះ។

**ប្រការ៣ .-**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបិទផ្សាយជាសាធារណៈនូវប្រកាសរួម ព្រមទាំងតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមនេះ។

**ប្រការ៤ .-**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវកំណត់អំពីនីតិវិធីសម្រាប់អនុវត្តការពិន័យជាប្រាក់ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាពិសេសត្រូវទុករយៈពេលមួយសមស្របសម្រាប់ការបង់ប្រាក់ពិន័យចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីការងារ។

**ប្រការ៥ .-**

ការបែងចែកភារកិច្ចលើការគ្រប់គ្រង និងការប្រមូលចំណូល រវាងរដ្ឋបាលកណ្តាលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវផ្ញើប្រកាសនេះចំនួនមួយច្បាប់មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជ្រាបជាព័ត៌មាន និងសម្រាប់តាមដានការអនុវត្តចំណូល។

**ប្រការ៦ .-**

រាល់ការប្រមូល ឬ ការទទួលប្រាក់ចំណូលជាសាច់ប្រាក់ ឬ ជាមូលប្បទានប័ត្រ លើការពិន័យជាប្រាក់ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីការងារ ដែលមានចែងនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមនេះ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ ដែលបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ ដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៧ .-**

រដ្ឋបាលកណ្តាលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវទទួលខុសត្រូវប្រាក់កាសលើប្រាក់ចំណូលប្រមូលបាន, បង់ប្រាក់ចំណូល និងផ្ញើសលាកប័ត្រចំណូលថវិកាជាតិ ព្រមទាំងចុះកិច្ចបញ្ជិកាគណនេយ្យស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាចំណូលថវិកា។

**ប្រការ៨ .-**

ប្រាក់ចំណូលដែលប្រមូលបានពីការពិន័យជាប្រាក់ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីការងារ ត្រូវបានបែងចែកដូចខាងក្រោម ÷

១- ការពិន័យជាប្រាក់ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ក. ការបែងចែកសម្រាប់រដ្ឋបាលកណ្តាល

- បង់ចូលថវិកាជាតិ ចំនួន ៣០% នៃប្រាក់ពិន័យដែលប្រមូលបាន
- ផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន ៦៩% នៃប្រាក់ពិន័យដែលប្រមូលបាន
- ផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ១% នៃប្រាក់ពិន័យដែលប្រមូលបាន។

ខ. ការបែងចែកសម្រាប់មន្ទីរជំនាញរាជធានី ខេត្ត

- បង់ចូលថវិកាជាតិ ចំនួន ៣០% នៃប្រាក់ពិន័យដែលប្រមូលបាន
- ផ្តល់រង្វាន់លើកទឹកចិត្តជូនមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ចំនួន ៦៩% នៃប្រាក់ពិន័យ ដែលប្រមូលបាន
- ផ្តល់រង្វាន់លើកទឹកចិត្តជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ចំនួន ១% នៃប្រាក់ពិន័យដែលប្រមូលបាន។

២- ការពិន័យជាប្រាក់ អនុលោមតាមការសម្រេចរបស់សាលាជម្រះក្តី

ក. ការបែងចែកសម្រាប់រដ្ឋបាលកណ្តាល

- បង់ចូលថវិកាជាតិ ចំនួន ២៦% នៃប្រាក់ពិន័យដែលប្រមូលបាន
- ផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន ៤៩% នៃប្រាក់ពិន័យដែលប្រមូលបាន
- ផ្តល់រង្វាន់លើកទឹកចិត្តសរុបជូនសាលាជម្រះក្តីពាក់ព័ន្ធ ចំនួន ២៤% នៃប្រាក់ពិន័យដែលប្រមូលបាន
-ផ្តល់រង្វាន់លើកទឹកចិត្ត ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ១% នៃប្រាក់ពិន័យដែលប្រមូលបាន។

ខ. ការបែងចែកសម្រាប់មន្ទីរជំនាញរាជធានី ខេត្ត

- បង់ចូលថវិកាជាតិ ចំនួន ២៦% នៃប្រាក់ពិន័យដែលប្រមូលបាន
- ផ្តល់រង្វាន់លើកទឹកចិត្តជូនមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ចំនួន ៤៩% នៃប្រាក់ពិន័យ ដែលប្រមូលបាន
- ផ្តល់រង្វាន់លើកទឹកចិត្តសរុបជូនសាលាជម្រះក្តីពាក់ព័ន្ធ ចំនួន ២៤% នៃប្រាក់ពិន័យដែលប្រមូលបាន
- ផ្តល់រង្វាន់លើកទឹកចិត្តជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ចំនួន ១% នៃប្រាក់ពិន័យដែលប្រមូលបាន។

**ប្រការ៩ .-**

អនុញ្ញាតឱ្យរដ្ឋបាលកណ្តាលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត កាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់លើកទឹកចិត្តសរុប ដោយដកយកពីប្រាក់ពិន័យដែលប្រមូលបានរៀងៗខ្លួន ដើម្បីចាត់ចែងបើកផ្តល់ជូនអង្គភាពគោលដៅដែលបានកំណត់នៅក្នុងប្រការ ៨ នៃប្រកាសរួមនេះ។ ការកាត់ទុកប្រាក់ចំណូលនេះ ត្រូវបានចាត់ទុកថារដ្ឋបាលកណ្តាលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត បានបុរេប្រទានថវិកាពីចំណូលថវិកាជាតិ។

ប្រការ១០ .-

រដ្ឋបាលកណ្តាលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវគ្រោងចំណូលសរុប និងចំណាយសម្រាប់ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត នៅក្នុងគម្រោងចំណូល និងចំណាយនៃថវិកាប្រចាំឆ្នាំរបស់ខ្លួនដោយឡែកពីគ្នា។ រដ្ឋបាលកណ្តាលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវគ្រោងឥណទានប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទានសម្រាប់ការចំណាយលើប្រាក់រង្វាន់របស់រដ្ឋបាលកណ្តាលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងប្រាក់រង្វាន់របស់សាលាជម្រះក្តី។ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវគ្រោងឥណទានប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទានសម្រាប់ការចំណាយលើប្រាក់រង្វាន់របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត និងប្រាក់រង្វាន់របស់សាលាជម្រះក្តី។ ឥណទានដែលបានគ្រោងសម្រាប់ការចំណាយលើប្រាក់រង្វាន់ ជាកម្មវត្ថុនៃការធ្វើអាណត្តិបើកប្រាក់ ដើម្បីទូទាត់ជាមួយចំនួនទឹកប្រាក់ដែលចាត់ទុកថាបានបុរេប្រទានពីចំណូលថវិកាជាតិ(រង្វាន់ដែលបានកាត់ទុក)។

រាល់ប្រតិបត្តិការនៃចំណូល និងចំណាយទាំងនេះ ត្រូវកត់ត្រាឆ្លុះបញ្ចាំងក្នុងថវិកាជាតិ ដូចប្រតិបត្តិការនៃចំណូល និងចំណាយដទៃទៀតរបស់រដ្ឋបាលកណ្តាល និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែរ។

ប្រការ១១ .-

ការគណនា ការកាត់ទុក ការប្រើប្រាស់ និងការទូទាត់ប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវអនុលោមតាមការកំណត់នៃសារាចរណែនាំលេខ ០០១ សហវ.ចមព ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីគោលការណ៍ និងនីតិវិធីផ្តល់រង្វាន់លើកទឹកចិត្តលើការផ្តល់សេវាសាធារណៈ។

ប្រការ១២ .-

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ផ្ញើជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

របាយការណ៍ស្តីពីការអនុវត្តចំណូលពីការពិន័យជាប្រាក់ ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីការងារ ជាផ្នែកមួយនៃរបាយការណ៍រួមស្តីពីការអនុវត្តចំណូលរបស់រដ្ឋបាលកណ្តាលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត។

**ប្រការ១៣ .-**

កម្រិតទឹកប្រាក់នៃការពិន័យចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីការងារ និងការផ្តល់អត្រាប្រាក់រង្វាន់លើកទឹកចិត្តជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អាចកែប្រែបានតាមការចាំបាច់ ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ប្រការ១៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសរួមនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៥ .-**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោមឱវាទក្រសួងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រមទាំងសាលាជម្រះក្តីគ្រប់ថ្នាក់ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

រដ្ឋមន្ត្រី
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

អ៊ិត សំហេង

កន្លែងទទួល :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត
- ដូចប្រការ១៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ